**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**២៩៣.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់វិទ្យាស្ថានខ្មែរជំនាន់ថ្មី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពី ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

មាត្រា ១ : ទទួលស្គាល់វិទ្យាស្ថានខ្មែរជំនាន់ថ្មី ដែលមានអក្សរកាត់ " វ.ខ.ថ. " និងជាភាសាអង់គ្លេសថា Institute of New Khmer ដែលមានអក្សរកាត់ " I.N.K "។ វិទ្យាស្ថាននេះ ស្ថិតនៅ

ក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅអគារលេខ១៤០ ផ្លូវលេខ ២៥៣ ភូមិ១២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មាត្រា ២ : វិទ្យាស្ថានខ្មែរជំនាន់ថ្មី មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់វិញ្ញាបនបត្រ សិក្សារយៈពេលយ៉ាងតិច ០១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ ត្រូវនឹង ៣០ ក្រេឌីតឡើងទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ០២ឆ្នាំ ត្រូវនឹង ៦០ក្រេឌីតឡើងទៅ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច០៤ឆ្នាំ ត្រូវនឹង១២០ក្រេឌីតឡើងទៅ
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សាយ៉ាងតិចរយៈពេល០២ឆ្នាំ ត្រូវនឹង៤៥ក្រេឌីតឡើងទៅ។

មាត្រា ៣ : ចំពោះមុខ វិទ្យាស្ថានខ្មែរជំនាន់ថ្មី មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យបច្ចេកទេស
- ការិយាល័យសិក្សា
- ការិយាល័យផែនការ និង ហិរញ្ញវត្ថុ
- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និង ភាសា
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
- មហាវិទ្យាល័យវិស្វកម្ម និង វិទ្យាសាស្ត្រកុំព្យូទ័រ

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកសាខា ឬមហាវិទ្យាល័យ ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ៤: លក្ខខណ្ឌទទួលសិស្ស-និស្សិត ឲ្យចូលរៀន ៖

- ថ្នាក់វិញ្ញាបនបត្រ បេក្ខជនជាសិក្ខា កាមសិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ កម្រិត៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនមានសញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋាននានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសការបណ្តុះបណ្តាល ការប្រឡងបញ្ចប់ការសិក្សារបស់សិស្ស និស្សិត។

មាត្រា ៥: វិទ្យាស្ថានខ្មែរជំនាន់ថ្មី មាននាយកមួយរូប និង មាននាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យបានទៀងទាត់តាមការកំណត់។

មាត្រា ៦: សិស្ស-និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ នឹងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឲ្យដោយវិទ្យាស្ថានខ្មែរជំនាន់ថ្មី នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ៧: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៨: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានខ្មែរជំនាន់ថ្មី ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *សាលារាជធានីភ្នំពេញ*
- *ដូចមាត្រា ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*